**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ម៉ាន់ ឡុង ស៊ូ ឯ.ក**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល៣១ថ្ងៃ

ថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង១:00 នាទីរសៀល មានកិច្ចប្រជុំមួយនៅរោងចក្រ ម៉ាន់ ឡុង ស៊ូ ឯ.ក មានអាសយដ្ឋានស្ថិតនៅភូមិឈើទាល ឃុំផ្តៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដោយមានលោក YANG GUO ZHONG ជានាយកក្រុមហ៊ុន បានបើកកិច្ចប្រជុំមួយជាមួយ

លោក ឡេង សុវណ្ណ និងលោកស្រី អួន សុឡាង ជាប្រតិភូបុគ្គលិក ដែលតំណាងអោយកម្មករនិយោជិតសរុប១៣៨នាក់។

ជាកិច្ចចាប់ផ្តើមលោក YANG GUO ZHONG ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូបុគ្គលិកទាំងអស់ដែលបានចូលរួម និង បានបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតនៅផ្នែក QC-C ផ្នែកខ្សែទឹកហូរ ផ្នែកផលិតផល ផ្នែករោងជាង ផ្នែកឈូសបាត ចំនួន៥៤នាក់ សម្រាប់រយៈពេល៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃ

ទី០១ ខែតុលា ឆ្នាំ២០២៤ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ ដោយសារស្ថានភាព បញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមកភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភ

ជូន កម្មករនិយោជិតម្នាក់ៗចំនួន៣០ដុល្លារ ក្នុងកំឡុងពេលនៃការព្យួរនេះនិងបើកជូនបងប្អូនកម្មករ និយោជិតនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៤។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង២:០០ នាទីរសៀល នៅថ្ងៃខែឆ្នាំដដែល ក្រោមស្មារតីយោគយល់គ្នា និង ទទួលយកនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

ជើងព្រៃ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤

**ភាគីទាំងពីរបានឯកភាព និង ផ្តិតមេដៃទុកជាភស្តុតាង**

**តំណាងក្រុមហ៊ុន**

YANG GUO ZHONG

**ប្រតិភូបុគ្គលិក**

១. លោក ឡេង សុវណ្ណ

២. លោកស្រី អួន សុឡាង